# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៦ អនក្រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញតម្រូវការចាំបាច់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**ប្រការ១:** បង្កើតអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារ ដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ដែលមានសមាសភាពដូចតទៅ៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ហួ ទិចិត្រ** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២- | ឯកឧត្តម លោកជំទាវ | **រដ្ឋលេខាធិការ** | តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- | ឯកឧត្តម | **ឆាយ ផាត** | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម | **គីមរ៉េត សំរេច** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- | ឯកឧត្តម | **សុខ ខាច់ាន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៦- | ឯកឧត្តម លោកជំទាវ | **ឯកអគ្គរាជទូត** | ប្រចាំព្រះរាជាណាចក្រថៃ | សមាជិក |
| ៧- | ឯកឧត្តម | **ឡាំ ជា** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- | ឯកឧត្តម | **អ៊ិត សុន្ថា** | ទីប្រឹក្សាអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និង ជាអនុរដ្ឋលេខាធិការ | សមាជិក |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| | | | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | |
| ៩- | ឯកឧត្តម | **កៅ ធារ៉ូ** | អនុរដ្ឋលេខាធិការ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១០- | ឯកឧត្តម | **ឃុន មុន្នីរិទ្ធ** | អគ្គលេខាធិការរង គណៈកម្មាធិការជាតិ សន្តិសុខលម្ហសមុទ្រ | សមាជិក |
| ១១- | ឯកឧត្តម | **ស៊ា ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១២- | ឯកឧត្តម | **ឡៀប សួរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- | ឯកឧត្តម | **ចាន់ រតនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានច្បាប់-កុងស៊ុលនិងព្រំដែន នៃក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤- | ឯកឧត្តម | **គង់ ច័ន្ទចារសនា** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិកនិង លេខាធិការ |
| ១៥- | ឯកឧត្តម | **ហាក់ សុខហេង** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិកនិង លេខាធិការ |
| ១៦- | លោកស្រី | **ម៉ៅ ភាន់នីភា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៧- | លោក | **ហួយ ឧត្តរា** | ប្រធាននាយកដ្ឋានសិក្សាស្រាវជ្រាវ ប្រេងកាត ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៨- | លោក | **លឹម ចន្ថា** | ប្រធាននាយកដ្ឋានកិច្ចការប្រេងកាត អន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៩- | លោក | **កែវ ទិសិដ្ឋ** | អធិការ នៃអគ្គាធិការដ្ឋាន ក្រសួងរ៉ែ និងថាមពល | សមាជិក និង លេខាធិការ |

**ប្រការ២:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ មានភារកិច្ចដូចតទៅ៖

(ក)- ជាយន្តការឆ្លើយតប ក្នុងកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រថៃ ក្នុងដំណើរការចរចាដោះស្រាយ តំបន់ទាមទារដែនសមុទ្រត្រួតគ្នា កម្ពុជា-ថៃ ។

(ខ)- ជាយន្តការសមភាគី ជាមួយអនុគណៈកម្មាធិការបច្ចេកទេសចម្រុះថ្មី ដែលព្រះរាជាណាចក្រថៃទើបនឹងបង្កើតឡើង។

**ប្រការ៣:** គ្រប់សមាជិកនៃអនុគណៈកម្មាធិការបច្ចេកទេសចម្រុះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញ របស់ប្រធាន ឬ អនុប្រធាន។

**ប្រការ៤:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានទីស្នាក់ការរបស់ខ្លួន នៅទីស្ដីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥:** អនុគណៈកម្មាធិការបច្ចេកទេសចម្រុះ មានសិទ្ធិប្រើប្រាស់មូលនិធិ របស់គណៈកម្មាធិការបច្ចេកទេសចម្រុះទទួលបន្ទុកការកំណត់ព្រំដែន និងការអភិវឌ្ឍរួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ សម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ៦**: សេចក្តីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួនដូចមាន ចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com